**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ ៤៣៥ សជណ.កអ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ករណីសំណើសុំការអនុញ្ញាតបើកឱ្យចិញ្ចឹមត្រីរស់ ត្រីឆ្តោឡើងវិញ ដើម្បីបង្កើនប្រាក់ចំណូល និងការងារជូនប្រជាពលរដ្ឋ។

**យោង ៖** - លិខិតលេខ ២៨៨៦ កសក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

- ចំណារ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាល សម្រេចដូចខាងក្រោម៖

- អនុញ្ញាតឱ្យមានការចិញ្ចឹមត្រីរស់និងការចិញ្ចឹមត្រីឆ្តោជាលក្ខណៈទូទៅ (គ្រួសារ និងពាណិជ្ជកម្ម) ឡើងវិញ។

- ការចិញ្ចឹមត្រីរស់និងត្រីឆ្តោជាលក្ខណៈពាណិជ្ជកម្ម ត្រូវមានភ្ជាប់នូវលក្ខខណ្ឌមួយចំនួនដើម្បីងាយស្រួលគ្រប់គ្រងនិងផ្តល់បច្ចេកទេសព្រមទាំងការព្យាបាលជំងឺ។ លក្ខខណ្ឌនៃការចិញ្ចឹមត្រីនេះ ត្រូវចេញដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងធានាឱ្យបាននូវបទដ្ឋានបច្ចេកទេសសមស្រប និរន្តរភាពធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប៊ុន អ៊ុយ

**ចម្លងជូន:**
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-ក្រសួងធនធានទឹកនិងឧតុនិយម
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
-រដ្ឋបាលជលផល
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៥៥៦ កសក

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០១៦

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** ៖ សំណើសុំការអនុញ្ញាតបើកឱ្យចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោ ឡើងវិញដើម្បីបង្កើនប្រាក់ចំណូលនិងការងារជូនប្រជាពលរដ្ឋ។

**យោង** ៖ - លិខិតលេខ៤០០៤ កសក.សជណ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ១៦០៥ សជណ.កស ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ៤៥៤៥ កសក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ១០៧១ សជណ.សរ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ១២៤៥ សជណ.កស ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើនេះ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញសេចក្តីជូនដំណឹងផ្អាកជាបណ្តោះអាសន្ននូវសកម្មភាពចិញ្ចឹមត្រីរ៉ស់និងត្រីឆ្តោ តាំងពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៤ រហូតដល់បច្ចុប្បន្ន ក្រោមហេតុផលថា៖

- ត្រីរ៉ស់និងត្រីឆ្តោ ជាប្រភេទត្រីស៊ីចំណីកូនត្រីស្រស់ល្អិតៗ
- មិនមានចំណីសិប្បនិម្មិតសម្រាប់ការចិញ្ចឹមត្រីរ៉ស់និងត្រីឆ្តោទេ
- ការចិញ្ចឹមត្រីរ៉ស់និងត្រីឆ្តោដោយប្រើកូនត្រីល្អិតជាចំណីបានបង្កឱ្យមានបទល្មើសនេសាទតាមរយៈការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុងចាប់ត្រីល្អិតៗដែលពិបាកក្នុងការទប់ស្កាត់។

ក្នុងបរិបទបច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញថា ៖
- ប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេ បឹង ព្រែក មួយចំនួនបាននាំគ្នាចិញ្ចឹមត្រីទាំងពីរប្រភេទនេះជាលក្ខណៈគ្រួសារជាយូរលង់ណាស់មកហើយ ដើម្បីបង្កើនប្រាក់ចំណូលដែលរដ្ឋបាលជលផលមានការលំបាកយ៉ាងខ្លាំងក្នុងការទប់ស្កាត់ទម្លាប់ចិញ្ចឹមត្រីទាំងពីរប្រភេទនេះឱ្យមានប្រសិទ្ធភាព
- ត្រីរ៉ស់និងត្រីឆ្តោជាប្រភេទត្រីមានតម្លៃសេដ្ឋកិច្ចខ្ពស់ហើយមានការនិយមចូលចិត្តបរិភោគជាទូទៅសម្រាប់ប្រជាពលរដ្ឋទាំងក្នុងនិងក្រៅប្រទេស
- ការសិក្សាស្រាវជ្រាវចម្បងៗនៃប្រទេសជិតខាងកម្ពុជាជាច្រើនឆ្នាំកន្លងមក ដែលប្រទេសកម្ពុជាក៏បានចូលរួមសហការផងដែរនោះបានបង្ហាញថា គេអាចចិញ្ចឹមត្រីរ៉ស់បានតាមរយៈការផ្តល់ចំណីសិប្បនិម្មិត (ចំណីគ្រាប់) ហើយមានការលូតលាស់លឿនជាងការផ្តល់ចំណីជាប្រភេទកូនត្រីទៅទៀតផង។ ដូច្នេះ ការចិញ្ចឹមត្រីរ៉ស់លែងចោទជាបញ្ហាទៀតហើយ ពោលគឺត្រីរ៉ស់អាចអនុញ្ញាតឱ្យចិញ្ចឹមជាទូទៅបាន

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- មានការផលិតចំណីសិប្បនិម្មិតសម្រាប់ការចិញ្ចឹមត្រីរស់ ដែលអាចនាំចូលពីប្រទេសថៃ និងវៀតណាម បានយ៉ាងគ្រប់គ្រាន់
- ចំពោះប្រភេទត្រីឆ្តោពុំទាន់មានការស្រាវជ្រាវណាមួយបង្ហាញថា ប្រភេទត្រីនេះអាចចិញ្ចឹមដោយប្រើចំណីសិប្បនិម្មិតជំនួសត្រីល្អិតបាននៅឡើយទេ ទោះបីរដ្ឋបាលជលផលបានសហការជាមួយប្រទេសជិតខាងស្រាវជ្រាវជាច្រើនឆ្នាំហើយក៏ដោយ។ ប៉ុន្តែស្ថានភាពនៃប្រទេសកម្ពុជា លទ្ធភាពនៃការចិញ្ចឹមត្រីឆ្តោនៅតែអាចធ្វើបានដោយកត្តាពីរយ៉ាងគឺ៖
    - មានប្រភេទត្រីសមុទ្រល្អិតៗប្រមាណជា៦០ ០០០តោន/ឆ្នាំ ដែលគេយកមកធ្វើជី និងកិនធ្វើជាចំណីសត្វឬនាំចេញទាំងស្រស់សម្រាប់ចិញ្ចឹមត្រីឆ្តោទៅប្រទេសជិតខាងកម្ពុជាជាដដែល។
    - ក្រៅពីប្រភេទត្រីល្អិតគឺមានចំណីផ្សេងទៀតសម្រាប់ការចិញ្ចឹមត្រីឆ្តោបានដូចជា៖
        - ○សាច់ខ្យងមាស (ដែលបំផ្លាញដំណាំស្រូវ)
        - ○សាច់កណ្តុរ ដែលអាចប្រមូលផលបានរាប់តោនក្នុងមួយថ្ងៃៗ
        - ○កាកសំណល់ផ្សេងៗពីសត្តឃាតដ្ឋានបន្ថែមទៀត។
    - ដោយយល់ឃើញពីសារៈសំខាន់នៃវិស័យជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបន្តទំនាក់ទំនងសហការជាមួយប្រទេសជិតខាង និងអង្គការនានាក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៀតលើបច្ចេកទេសចិញ្ចឹមត្រីឆ្តោដើម្បីជំរុញវិស័យនេះឲ្យមានការរីកចម្រើនក្នុងទិសដៅផ្គត់ផ្គង់តម្រូវការទីផ្សារឲ្យបានគ្រប់គ្រាន់។

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា ក្នុងចតុកោណទី១ ការលើកស្ទួយវិស័យកសិកម្ម មុំទីមួយ ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ផែនការអភិវឌ្ឍវិស័យកសិកម្ម ២០១៤-២០១៨ ព្រមទាំងផែនការអភិវឌ្ឍន៍ជលផល១០ឆ្នាំ (២០១០-២០១៩)។ ដោយសារវិស័យជលផលជាពិសេសការធ្វើវារីវប្បកម្មមានការពាក់ព័ន្ធក្នុងការបម្រើជីវភាពប្រជាជនប្រចាំថ្ងៃនោះ ខ្ញុំបាទសូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោ** ស្នើសុំលើកសំណូមពរដូចខាងក្រោម៖

- ស្នើសុំអនុញ្ញាតឲ្យមានការចិញ្ចឹមត្រីរស់និងការចញ្ចឹមត្រីឆ្តោជាលក្ខណៈជាទូទៅ (គ្រួសារ និងពាណិជ្ជកម្ម) ឡើងវិញ
- ការចិញ្ចឹមត្រីរស់និងត្រីឆ្តោជាលក្ខណៈពាណិជ្ជកម្ម អាចអនុញ្ញាតបានដោយមានភ្ជាប់នូវលក្ខខណ្ឌមួយចំនួនដើម្បីងាយស្រួលគ្រប់គ្រងនិងផ្តល់បច្ចេកទេសព្រមទាំងការព្យាបាលជំងឺ។ លក្ខខណ្ឌនៃការចិញ្ចឹមត្រីនេះត្រូវចេញដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងធានាឲ្យបាននូវបទដ្ឋានបច្ចេកទេសសមស្រប និរន្តរភាពធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន។

អាស្រ័យហេតុនេះ ខ្ញុំបាទសូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាពិនិត្យ សម្រេច និងផ្តល់មតិណែនាំដោយអនុគ្រោះបំផុត។

សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**